ស្ថានទូតអូស្ត្រាលី ភ្នំពេញ

# <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៨

## ដំណើរទស្សនកិច្ចរបស់ឯកអគ្គរាជទូតអូស្ត្រាលី
## សម្រាប់កិច្ចការស្ត្រីនិងកុមារី

ឯកអគ្គរាជទូតអូស្ត្រាលីសម្រាប់កិច្ចការស្ត្រីនិងកុមារី អ្នកស្រីបណ្ឌិត **ហ្សារ៉ាមែន ស្តូន** នឹងអញ្ជើញមកទស្សនកិច្ចនៅកម្ពុជានាថ្ងៃទី១-២ ខែកុម្ភៈ ឆ្នាំ២០១៨។

ក្នុងឱកាសនៃដំណើរទស្សនកិច្ចនេះ អ្នកស្រីបណ្ឌិត **ស្តូន** នឹងចុះពិនិត្យដោយផ្ទាល់នូវលទ្ធផលអភិវឌ្ឍន៍សម្រាប់ស្ត្រីនិងកុមារី ក្រោមកម្មវិធីជំនួយអភិវឌ្ឍន៍អូស្ត្រាលីនៅកម្ពុជា។

អ្នកស្រីនឹងជួបជាមួយស្ថាបនិកគេហទំព័របងស្រី ដែលជាគំនិតផ្តួចផ្តើមថ្មីមួយក្នុងការផ្តល់ឱកាសការងារ និងសេវាបញ្ជូនបន្ត ចំពោះកម្មករដែលមានជំនាញទាប ដែលភាគច្រើនគឺជាស្ត្រី។ គេហទំព័របងស្រី បានទទួលជំនួយតាមរយៈវេទិកាភាពជាដៃគូធុរកិច្ចនៃរដ្ឋាភិបាលអូស្ត្រាលី ដែលបានប្រកាសដោយរដ្ឋមន្ត្រីការបរទេសអូស្ត្រាលី លោកជំទាវ **ជូលី ប៊ីហ្សប** កាលពីខែវិច្ឆិកា ឆ្នាំ២០១៧។

អ្នកស្រីបណ្ឌិត **ស្តូន** នឹងចុះពិនិត្យការងារនៅរោងចក្រកាត់ដេរ ក្រោមកម្មវិធីរបស់រដ្ឋាភិបាលអូស្ត្រាលីក្នុងការជួយគាំទ្រដល់អង្គការដែលផ្តល់សេវាកម្មផ្នែកសុខភាពបន្តពូជ និងការរៀបចំផែនការគ្រួសារ។

អ្នកស្រីបណ្ឌិត **ស្តូន** នឹងជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំជាស្ត្រីក្នុងជួររដ្ឋាភិបាល អង្គការអភិវឌ្ឍន៍ និងសង្គមស៊ីវិល ដើម្បីស្វែងយល់អំពីការងារដ៏អស្ចារ្យដែលពួកគេកំពុងបំពេញក្នុងការជួយជំរុញសមភាពយេនឌ័រនៅកម្ពុជា។

ទំនាក់ទំនងព័ត៌មាន៖ Australian.Embassy.Cambodia@dfat.gov.au